# អេស៊ីលីដា ACLEDA BANK

សាខា (Branch):

# ទម្រង់ផ្ទេរប្រាក់ក្រៅប្រទេស
## Overseas Transfer Application Form

## សម្រាប់អតិថិជន (For customer)

**ព័ត៌មានអ្នកស្នើសុំ: (Applicant details) 50**

ឈ្មោះ (Name):
លេខអត្តសញ្ញាណប័ណ្ណ (ID number):
លេខទូរសព្ទ (Telephone number):
ឈ្មោះ ឬលេខអគារ (Building name or №):
ឈ្មោះ ឬលេខផ្លូវ (Street name or №):
ក្រុមទី (Group №): ភូមិ (Village): ឃុំ/សង្កាត់ (Commune):
ស្រុក/ខណ្ឌ/ក្រុង (District/City): ខេត្ត/រាជធានី (Province/Capital): ប្រអប់សំបុត្រ (P.O.Box):

កាលបរិច្ឆេទ: Confirmed date dd mm yy

ប្រភេទរូបិយប័ណ្ណ (Currency type)
☐ ប្រាក់ដុល្លារ (USD) ☐ ប្រាក់បាត (THB)
☐ ប្រាក់អឺរ៉ូ (EUR) ☐ ផ្សេងៗ: (Other):

**ចំនួនទឹកប្រាក់ក្នុងការផ្ទេរ:** (Amount of transfer) 32A
ចំនួនទឹកប្រាក់ជាលេខ (Amount in figures):
ចំនួនទឹកប្រាក់ជាអក្សរ (Amount in words):

**ព័ត៌មានធនាគារអន្តរការី:** (Intermediary bank) 56
ឈ្មោះធនាគារអន្តរការី (Name of intermediary bank):
អាសយដ្ឋាន (Address):

**ព័ត៌មានធនាគារទទួលផល:** (Beneficiary's bank details) 57
ឈ្មោះធនាគារទទួលផល (Name of beneficiary's bank):
លេខកូដ SWIFT (SWIFT code):
អាសយដ្ឋាន (Address):

**ព័ត៌មានអ្នកទទួលប្រាក់ (Beneficiary details) 59**
ឈ្មោះ (Name):
គណនីលេខ (Account number/IBAN):
ប្រភេទរូបិយប័ណ្ណ (Currency type): ☐ ប្រាក់ដុល្លារ (USD) ☐ ពុំដឹងច្បាស់ (Unknown) ☐ ផ្សេងៗ (Other):
ប្តូរប្រាក់នៅ (Currency exchange within): ☐ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA Bank Plc.) ☐ ធនាគារក្រៅប្រទេស (Overseas bank)
អាសយដ្ឋាន (Address): លេខទូរសព្ទ (Tel No.):

**គោលបំណងនៃការផ្ទេរប្រាក់:** (Purpose of transfer) 70
☐ ផ្ញើឱ្យបងប្អូន (Send to a relative) ☐ ទូទាត់ឥណទាន (Loan repayment) ☐ ផ្សេងៗ (Other):
☐ ទូទាត់ថ្លៃទំនិញ/វិក្កយបត្រ (Pay for goods/invoice):

**ទំនាក់ទំនងហិរញ្ញវត្ថុ (សូមមើលលក្ខខណ្ឌទំព័រខាងក្រោយ)**/Financial Relationship (Please see the back page): ○ មាន (R) ○ គ្មាន (N) ○ មិនដឹង (DN)

**ទូទាត់តាមរយ:** (Payment methods)
☐ យើងខ្ញុំសូមទូទាត់ជាសាច់ប្រាក់ (I/We shall pay cash)
☐ សូមភ្ជាប់មកជាមួយនូវមូលប្បទានបត្រលេខ (I/We enclose check number): Bank name:
☐ សូមដកទឹកប្រាក់ពីគណនី/គណនីរក្សាសុវត្ថិភាពសាច់ប្រាក់យើងខ្ញុំលេខ: (Please debit from my/our account/cash custody account number)
☐ គណនីរក្សាសុវត្ថិភាពមូលបត្រលេខ (Securities custody account number):

ការចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើទម្រង់នេះគឺមានន័យថា លោកអ្នកបានអានយល់ច្បាស់ និងយល់ព្រមនូវរាល់លក្ខខណ្ឌ និងខចែងដែលមាននៅទំព័រខាងក្រោយ។ លោកអ្នកទទួលខុសត្រូវនូវរាល់ព័ត៌មានដែលលោកអ្នកបានផ្តល់ឱ្យធនាគារ។ ធនាគារ អេស៊ីលីដា មិនទទួលខុសត្រូវនូវរាល់ការយឺតយ៉ាវកំហុសឆ្គង ឬការខកខានណាមួយដោយសារព័ត៌មានដែលលោកអ្នកបានផ្តល់ឱ្យមិនត្រឹមត្រូវ។
ខ្ញុំយល់ព្រម ចំពោះការផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងគោលបំណងផ្តល់ការផ្ទេរប្រាក់អន្តរជាតិ និងផ្តល់សិទ្ធិអនុញ្ញាតឱ្យធនាគារបង្ហាញ ទៅអាជ្ញាធរពាក់ព័ន្ធ ក៏ដូចជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬដៃគូរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចមានចែងក្នុងទម្រង់នេះ។ អ្នកអាចស្វែងរកព័ត៌មានបន្ថែម នៅលើគេហទំព័រផ្លូវការរបស់យើង៖ **https://www.acledabank.com.kh/kh/khm/legal_privacy_notice**

By signing or fingerprint this application form, you acknowledged that you have read, understood, and agreed with all of the terms and conditions on the reverse of this form. You'll take all responsibilities for information provided. ACLEDA Bank will not responsible for any delay and mistakes resulted from incorrect information provided.

I expressly consent for the transfer of my personal data to facilitate the international money transfer. I authorize the bank to disclose this information with the relevant authorities, as well as with ACLEDA Bank's subsidiaries or partners, as outlined in this form. For more information, please visit our official website: **https://www.acledabank.com.kh/kh/eng/legal_privacy_notice**

ហត្ថលេខា ឬស្នាមម្រាមដៃអ្នកស្នើសុំ (Applicant's signature or fingerprint)

## សម្រាប់ធនាគារ/For bank use only

| **Denomination** | | |
|---|---|---|
| | Amount | |
| | Exchange rate @ | |
| | Equivalent | |
| | SWIFT charge | |
| | Processing fee | |
| | Local fee | |
| | Other | |
| | **Total** | |
| | Charges (71) | ☐ SHA ☐ BEN ☐ OUR |

| **Authorized by** | **Certified by** | **Prepared by** |
|---|---|---|
| | | |
| **Msg Authorized** | **Msg Certified** | **Msg Prepared** |
| | | |

# លក្ខខណ្ឌប្រតិបត្តិការសេវាផ្ទេរប្រាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី Terms and Conditions of Funds Transfer

សូមអានលក្ខខណ្ឌនេះដោយប្រុងប្រយ័ត្ន ដើម្បីយល់ឱ្យបានច្បាស់លាស់នូវសេវាផ្ទេរប្រាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ លក្ខខណ្ឌនេះ បង្កើតឡើងសម្រាប់ប្រើជាកិច្ចព្រមព្រៀងក្នុងប្រតិបត្តិការផ្ទេរប្រាក់រវាងលោក-លោកស្រី ជាមួយធនាគារ ។

**ការទទួលខុសត្រូវរបស់អតិថិជន**

១. លោក-លោកស្រីត្រូវប្រាកដថា រាល់ព័ត៌មានដែលបានបំពេញលើទម្រង់ផ្ទេរប្រាក់ពិតជាត្រឹមត្រូវ និងគ្រប់គ្រាន់។
២. ករណីមានការកែប្រែព័ត៌មាន ពន្យារពេលទូទាត់ ឬបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ លោក-លោកស្រីត្រូវ ជូនដំណឹងមកធនាគារ អេស៊ីលីដា ភីអិលស៊ី ជាលាយលក្ខណ៍អក្សរ ។
៣. លោក-លោកស្រីត្រូវទទួលខុសត្រូវទាំងស្រុងចំពោះច្បាប់ជាតិ និងអន្តរជាតិលើប្រតិបត្តិការផ្ទេរប្រាក់នេះ ក្នុងនាមខ្លួនឯងផ្ទាល់ និងសាច់ញាតិ ឬប្រតិបត្តិការទូទាត់ក្រោមកិច្ចសន្យា ។
៤. លោក-លោកស្រីត្រូវសហការក្នុងការផ្តល់ឯកសារគាំទ្រពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរប្រាក់ ករណីធនាគារមានតម្រូវការ ។
៥. ទំនាក់ទំនងហិរញ្ញវត្ថុ ជាទូទៅកើតមាននៅពេលដែលមានប្រតិបត្តិការពីររវាងក្រុមហ៊ុន-សហគ្រាស និងក្រុមហ៊ុន-សហគ្រាសដែលជាសម្ព័ន្ធញាតិនឹងគ្នា ។ នេះមានន័យថា បុគ្គលជាប្រតិបត្តិករអាចកាន់កាប់ភាគហ៊ុនមួយផ្នែក ឬទាំងស្រុងរបស់ប្រតិបត្តិករផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោល ។

**ទំនាក់ទំនងហិរញ្ញវត្ថុ**

មាន (R) : ក្រុមហ៊ុន-សហគ្រាសវិនិយោគផ្ទាល់ ជាការវិនិយោគរវាងប្រតិបត្តិករជានិវាសជន ឬអនិវាសជនជាមួយប្រតិបត្តិករអនិវាសជន ឬនិវាសជន ដែលមានភាគហ៊ុន ១០% ឬច្រើនជាង ១០% នៃក្រុមហ៊ុន-សហគ្រាសវិនិយោគផ្ទាល់ ។

គ្មាន (N) : បានន័យថាប្រតិបត្តិករជានិវាសជន ឬអនិវាសជនគ្មានភាគហ៊ុន ឬមានភាគហ៊ុនតិចជាង ១០% ជាមួយប្រតិបត្តិករជាអនិវាសជន ឬនិវាសជនផ្សេងទៀត ។

មិនដឹង (DN)

**ប្រតិបត្តិការផ្ទេរប្រាក់**

១. ប្រតិបត្តិការសេវាផ្ទេរប្រាក់នឹងត្រូវធ្វើឡើងក្រោយពេលធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានទម្រង់ផ្ទេរប្រាក់ពីលោក-លោកស្រី ។
២. ធនាគារនឹងធ្វើប្រតិបត្តិការទូទាត់ទៅតាមព័ត៌មានដែលបានបញ្ជាក់នៅក្នុងទម្រង់ផ្ទេរប្រាក់ប៉ុណ្ណោះ ដូច្នេះធនាគារនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ និងការចំណាយផ្សេងៗ ដែលបណ្តាលមកពីការផ្តល់ព័ត៌មានមិនត្រឹមត្រូវ មិនគ្រប់គ្រាន់ និងមិនច្បាស់លាស់នោះឡើយ ។
៣. ប្រតិបត្តិការផ្ទេរប្រាក់ជាប្រភេទរូបិយប័ណ្ណផ្សេងក្រៅពីរូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ទោះបីអ្នកទទួលផលមានគណនី ឬគ្មានគណនីក៏ដោយ គឺអាចដកបាននៅពេលធនាគារមានបម្រុងសាច់ប្រាក់រូបិយប័ណ្ណប្រភេទនោះគ្រប់គ្រាន់ប៉ុណ្ណោះ ។ បើមិនដូច្នោះទេ អតិថិជនត្រូវដកជាប្រាក់រៀល ឬដុល្លារអាមេរិក ដោយគិតទៅតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅពេលដកសាច់ប្រាក់នោះ ។
៤. ប្រតិបត្តិការផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនី៖
- ទឹកប្រាក់ផ្ទេរអាចស្ថិតនៅក្នុងគណនីព្យួររបស់ធនាគាររយៈពេល ៣៦០ថ្ងៃតែប៉ុណ្ណោះ ។ ដោយគិតចាប់ពីថ្ងៃផ្ទេរប្រាក់ អ្នកផ្ទេរត្រូវទំនាក់ទំនងអ្នកទទួលដើម្បីឱ្យមកដកប្រាក់ទាន់ពេលតាមការកំណត់ ។
- ក្រោយពីទទួលការផ្ទេរប្រាក់ចូលរយៈពេល ៣៦០ថ្ងៃ ដោយពុំមានអ្នកទទួលមកដកប្រាក់ (អ្នកទទួលគ្មានគណនី) ទឹកប្រាក់នោះត្រូវបានផ្ទេរចូលគណនីចំណូលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- ករណីអ្នកផ្ទេរ ឬអ្នកទទួល ត្រលប់មកដកប្រាក់ចាប់ពីថ្ងៃទី ៣៦១ តទៅ ត្រូវភ្ជាប់មកនូវឯកសារពាក់ព័ន្ធនៃការផ្ទេរប្រាក់ (សម្រាប់អ្នកផ្ទេរ) ឬសំណួរ-ចម្លើយ ឬលិខិតសម្គាល់អត្តសញ្ញាណ (សម្រាប់អ្នកទទួល) ធនាគារនឹងបង្វែរទឹកប្រាក់នោះជូនអ្នកផ្ទេរ ឬអ្នកទទួលវិញ ។

៥. ការបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ ធនាគារនឹងប្រគល់ជូនតែចំនួនប្រាក់ផ្ទេរប៉ុណ្ណោះ រីឯកម្រៃសេវា នឹងមិនបង្វែរជូនលោក-លោកស្រីវិញឡើយ ។ ចំពោះការផ្ទេរប្រាក់ទៅក្រៅប្រទេស នឹងទទួលបានទឹកប្រាក់ជាក់ស្តែងក្រោយពេលធនាគារនៅក្រៅប្រទេសបង្វែរទឹកប្រាក់នោះមកវិញ ឬពុំអាចទទួលទឹកប្រាក់បានឡើយប្រសិនបើអ្នកទទួលនៅក្រៅប្រទេស មិនអនុញ្ញាតឱ្យបង្វែរប្រាក់ត្រលប់ទៅលោក- លោកស្រីវិញ ។

**ប្រភេទរូបិយប័ណ្ណ**

ប្រតិបត្តិការផ្ទេរប្រាក់អាចធ្វើឡើងជាប្រភេទរូបិយវត្ថុប្រាក់រៀល រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក រូបិយប័ណ្ណប្រាក់បាតថៃ និងរូបិយប័ណ្ណផ្សេងៗទៀត ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ ករណីប្រតិបត្តិការផ្ទេរប្រាក់មានប្រភេទរូបិយប័ណ្ណផ្សេងគ្នា ត្រូវឆ្លងកាត់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅពេលទូទាត់ចូលគណនី ។

**កម្រៃសេវាផ្ទេរប្រាក់**

១. លោក-លោកស្រី ត្រូវពិនិត្យលើថ្លៃសេវាដែលធនាគារដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ឬថ្លៃសេវាដែលបានព្រមព្រៀងគ្នា ឱ្យបានច្បាស់លាស់ មុននឹងសម្រេចធ្វើប្រតិបត្តិការនីមួយៗ និងយល់ព្រមបង់ជាសាច់ប្រាក់ ឬឱ្យធនាគារកាត់កងទឹកប្រាក់ពីគណនីរបស់ខ្លួនដើម្បីទូទាត់កម្រៃសេវា និងការចំណាយផ្សេងៗដែលពាក់ព័ន្ធ ។
២. ថ្លៃសេវាលើប្រតិបត្តិការផ្ទេរប្រាក់ដែលបានព្រមព្រៀងរួចហើយ មិនអនុញ្ញាតឱ្យកែប្រែ ឬផ្លាស់ប្តូរដោយពុំមានការយល់ព្រមពីភាគីណាមួយឡើយ ។
៣. ចំពោះការផ្ទេរប្រាក់ទៅក្រៅប្រទេស តាមប្រព័ន្ធ SWIFT ធនាគារអាចស្នើសុំលោក-លោកស្រីឱ្យបង់កម្រៃសេវាបន្ថែមទៅលើការកែប្រែព័ត៌មាន ឬបន្ថែមព័ត៌មានករណីមានតម្រូវការពីធនាគារនៅក្រៅប្រទេស ។

**ការរក្សាការសម្ងាត់**

រាល់ព័ត៌មានផ្ទេរប្រាក់ ត្រូវបានរក្សាការសម្ងាត់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី លើកលែងតែករណីដូចជា៖

១. ធនាគារមានតម្រូវការព័ត៌មានសម្រាប់រៀបចំរបាយការណ៍ ឬសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ឬច្បាប់តម្រូវ ។
២. ករណីមានដីកាពីតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងស៊ើបអង្កេត ឬដំណើរការផ្លូវច្បាប់ទាក់ទងនឹងបទល្មើសដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ។

**ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**

លោក-លោកស្រីយល់ព្រមឱ្យធនាគារពន្យារពេលទូទាត់ បង្ខាំង ឬបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ ប្រសិនបើធនាគារ អេស៊ីលីដា ភីអិលស៊ី ឬធនាគារអន្តរការីរកឃើញថា៖

១. មានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសកម្មភាពមិនស្របច្បាប់ ។
២. បំពានលើច្បាប់ជាតិ ឬអន្តរជាតិ ។

**សំណងការខាតបង់**

១. លោក-លោកស្រីយល់ព្រមដោយគ្មានលក្ខខណ្ឌ ក្នុងការទូទាត់សំណងជូនធនាគារនូវរាល់ការខាតបង់ ការប្តឹងផ្តល់ ការទាមទារសំណង និងចំណាយផ្លូវច្បាប់ផ្សេងៗ ដែលបណ្តាលមកពីការធ្វើប្រតិបត្តិការផ្ទេរប្រាក់នេះ ។
២. លោក-លោកស្រី ត្រូវយល់ព្រមឱ្យធនាគារកាត់ទឹកប្រាក់ដែលមានក្នុងគណនីរបស់ខ្លួន សម្រាប់ទូទាត់សំណងដែលបានរៀបរាប់ខាងលើនេះ ទៅតាមស្ថានភាពជាក់ស្តែង ។

**ផ្សេងៗ**

១. លក្ខខណ្ឌនេះអាចនឹងធ្វើការកែប្រែជាបន្តបន្ទាប់ ដើម្បីឱ្យសមស្របជាមួយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
២. លក្ខខណ្ឌនេះត្រូវបានរៀបចំឡើងជាភាសាខ្មែរនិងភាសាអង់គ្លេស ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬមិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាបានការ ។
៣. ភាគីដែលពាក់ព័ន្ធ ពិតជាបានអាន និងយល់គ្រប់ចំណុចទាំងអស់ដែលមានចែងនៅក្នុងលក្ខខណ្ឌនេះ និងទទួលបានច្បាប់ចតចម្លងដែលមានចែងនៅផ្នែកខាងខ្នងនៃទម្រង់ផ្ទេរប្រាក់ចំនួន ០១ច្បាប់ ។

These terms and conditions are an "Agreement" between you and ACLEDA Bank Plc, please carefully read these terms and conditions to understand in relation to the use of Funds Transfer.

**CUSTOMER'S RESPONSIBILITY**

1- You must ensure that all information provided are true and correct.
2- In case of changing information, delaying payment, or cancelling funds transfer transaction, please notice to ACLEDA Bank in writing.
3- You are wholly responsible for Cambodia and international law on the funds transfer and guarantee that you are acting on your own and relatives or the settlement under the agreement.
4- You must to cooperate in providing related supporting documents in case of the bank requirement.
5- Financial Relationships occur when the two transactors, particular business enterprise are affiliated. This means one of transactor directly or indirectly holds partial or full ownership of another transactor.

**FINANCIAL RELATIONSHIP**

Relationship (R) : If the resident transactor/nonresident transactor is a direct investment enterprise (DIE) of nonresident transactor/resident transactor who has 10% or more of share ownership in DIE.

Non-Relationship (N) : If resident and nonresident transactors have no share ownership whatsoever or have share ownership less than 10%.

Don't know (DN)

**FUNDS TRANSFER**

1- Funds transferred by ACLEDA Bank will be made after the bank approves your transfer application.
2- ACLEDA Bank will make payment in accordance with the information specified in the application form, so the bank will not be liable for any costs or losses resulting from insufficient or wrong information given.
3- The funds transfer transaction in other currencies beside Khmer Riel and US Dollars, even though the beneficiary has an account or no account, the customer could be withdrawn when the bank has sufficient reserves of that currency. Otherwise, they have to withdraw in Khmer Riel or US Dollars according to the bank's prevailing currency exchange rate of ACLEDA Bank.
4- For Fund Transfer transactions to non-account recipient:
- For Fund Transfer transactions to non-account recipient, the transfer amount can be kept in the suspend account in 360 days only. Thus the sender has to contact the recipient to withdraw money timely.
- After receiving inward fund transfer in 360 days without the recipient's present (the recipient has no account), that amount will be delivered to the ACLEDA Bank's revenue account.
- In case of the sender or recipient comes to get fund from 361 period, she/he has to attach with fund transfer documents (for sender) or test question or identification document (for recipient) the bank will return fund to the sender or recipient after getting an approval from management.

5- For the termination of the transaction, ACLEDA Bank will return the transfer amount only whereas the transaction fee will not be returned. Overseas funds transfer, the customer will receive the actual amount after correspondent bank return the fund or will not receive, if the recipient at abroad does not allow to return to you.

**TYPE OF CURRENCY**

Available currencies for the remittance services are KHR, USD, THB and other currencies which ACLEDA Bank Plc. has officially launched. In case of any transaction in different currency, the amount of withdrawal will be converted to be KHR or USD according to the prevailing currency exchange rate of ACLEDA Bank at that time.

**FEES CHARGE**

1- You must check the officially service fees launched or the agreed fee before deciding on each transaction and agree to allow the bank to deduct money from their account to cover the fees and other related expenses.
2- The transaction fee that was already agreed will not allow any modification or change without the consent of the either parties.
3- For Overseas funds transfer via SWIFT, the Bank may request you to pay for additional fees on any information modifications or additional information needed by the correspondent bank at overseas.

**CONFIDENTIALITY**

ACLEDA Bank will not disclose all funds transfer information to any person, except to the following cases:

1- ACLEDA Bank requires information for preparing report or other relevant activities required by the law.
2- In case of court citation or authority use for investigating or processing any unlawful conduct whether you have involved directly or indirectly.

**ANTI-MONEY LAUNDERING AND COMBATING THE FINANCING OF TERRORISM**

You agree ACLEDA Bank may postpone, block or stop processing funds transfer if the ACLEDA bank Plc. or correspondent bank has found that the process may:

1- Directly or indirectly involve the proceeds of unlawful conduct; and
2- Breach any national or international law.

**INDEMNITY**

1- You unconditionally agree to indemnify and compensate the bank against all losses, claims, costs or expense which the bank may incur as a result of processing funds transfer.
2- You authorize the bank to debit cash from your account in order to indemnify all claims as mentioned above on the actual situation.

**OTHERS**

1- These terms and conditions are subject to change frequently in order to comply with the Cambodia law.
2- These terms and conditions are made in both Khmer and English, so if there is any inconsistency between Khmer and English versions, the terms of Khmer version shall prevail.
3- Relevant parties have read, understood, and agreed all points as mentioned in these terms and conditions and have received a copy of these terms and conditions that is written on the back of the fund transfer application form.